III.MD.pha.54

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៩ សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ ថាមពល កកើតឡើងវិញ និង បច្ចេកវិទ្យាថាមពល កម្ពុជា_ជប៉ុន

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងស្មារតីនៃជំនួបសំណេះសំណាលនៅតូក្យូ នាថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០១ រវាងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងលោក ស៊ុយតូម៉ុយ ម៉ាតឹល្វូ ប្រធានអង្គការណេដូ (NEDO)

## សំរេច

**ប្រការ ១.-** បង្កើតក្រុមការងារសហប្រតិបត្តិការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាថាមពល កម្ពុជា-ជប៉ុន ដែលមានសមាសភាពដូចតទៅ :

១- លោកបណ្ឌិត សាត សាមី ប្រធាននាយកដ្ឋានថាមពល ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធាន

២- លោកបណ្ឌិត ជា វ៉ាន់ដេត ជំនួយការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣- លោក អ៊ឹង សំអាត អនុប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

៤- លោក សាត សមុទ្រ ប្រធាននាយកដ្ឋានបច្ចេកវិទ្យាអគ្គិសនី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក

www.pheakdeylaw.com

៥- លោក ឆាយ ថៃ មន្ត្រីនៃអគ្គលេខាធិការដ្ឋាន OBSES សមាជិក

**ប្រការ ២ :** ក្រុមការងារនេះ មានបេសកកម្ម ដូចខាងក្រោម:

- ជំរុញលើកទឹកចិត្ត និង ធ្វើអោយប្រសើរឡើង ក្នុងការអភិវឌ្ឍវិស័យថាមពលកកើតឡើងវិញ ដោយអនុវត្តនូវបច្ចេកវិទ្យាប្រព័ន្ធថាមពលអគ្គិសនីគំរូ សំរាប់បង្ហាញ ផ្សព្វផ្សាយ ស្រាវជ្រាវ បណ្តុះបណ្តាល និងគ្រប់គ្រងអោយមានប្រសិទ្ធភាពនិងសុវត្ថិភាព ។
- អនុវត្តគំរោង និង តំលើងនូវប្រព័ន្ធថាមពលអគ្គិសនីគំរូ នៅតាមបណ្តាទីតាំងជាអាទិភាព ដូចជា មណ្ឌលសុខភាព មណ្ឌលកុមារកំព្រា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សាលារៀន វត្តអារាម និងភូមិគំរូ ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល ដើម្បីរួមចំណែកដល់ការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់ថាមពលអគ្គិសនីសំរាប់បំភ្លឺ បូមទឹកស្អាត ថែរក្សាវ៉ាក់សាំង ប្រើប្រាស់កុំព្យូទ័រ ប្រព័ន្ធទំនាក់ទំនង វិទ្យុ និងទូរទស្សន៍ ។ល។
- ធ្វើការអង្កេត ប្រមូលទិន្នន័យ សិក្សាស្រាវជ្រាវ វិភាគ វាយតំលៃ សំរាប់កសាងផែនការមេ លើវិស័យថាមពលកកើតឡើងវិញ និងព្រមទាំងកំណត់នូវសក្តានុពលនៃធនធាននីមួយៗ អោយបានច្បាស់លាស់ ក្នុងក្របខ័ណ្ឌទូទាំងប្រទេសកម្ពុជា ។
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ឬ ពហុភាគី ដោយធ្វើការផ្លាស់ប្តូរបទពិសោធន៍នូវពត៌មានវិទ្យា-បច្ចេកវិទ្យា និង ប្រមូលចងក្រងឯកសារ ដើម្បីជាមូលដ្ឋានគ្រឹះ និងជាទិសដៅឆ្ពោះទៅដល់ការផ្តល់ អនុសាសន៍ លើការរៀបចំយុទ្ធសាស្ត្រ គោលការណ៍ គោលនយោបាយ និង ផែនការសកម្មភាពរយៈពេលខ្លី-មធ្យម-វែង លើវិស័យថាមពលកកើតឡើងវិញ ដោយធានាបាននូវការថែរក្សាបរិស្ថាន ។
- ផ្សព្វផ្សាយ និងរៀបចំគោលនយោបាយអោយមានការលើកទឹកចិត្ត ដល់ការចូលរួមបន្ថែមទៀត ពីសំណាក់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ រួមទាំងផ្នែកឯកជនផងដែរ ។

**ប្រការ ៣:** ដើម្បីបំពេញបេសកកម្មខាងលើ ក្រុមការងារនេះមានភារកិច្ច និងតួនាទី :

- សំរបសំរួល និង សហការជាមួយអង្គការណេដូ (New Energy and Industrial Technology Development Organization, NEDO) ប្រទេសជប៉ុន ដើម្បីជំរុញការសិក្សា ស្រាវជ្រាវ អភិវឌ្ឍ និង ប្រើប្រាស់នូវបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- សំរបសំរួល និង សហការជាមួយបណ្តាក្រសួង ស្ថាប័នមានសមត្ថកិច្ចខេត្ត-ក្រុងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ក្រុមហ៊ុនឯកជន ដើម្បីជំរុញការអនុវត្តនិងការអភិវឌ្ឍ អោយមានប្រសិទ្ធភាព សុវត្ថិភាព ក្នុងអត្ថន័យការពារបរិស្ថាន ។
- ចូលរួមប្រជុំ និង ធ្វើទំនាក់ទំនងផ្ទាល់ ជាមួយអង្គការណេដូ ក៏ដូចជាអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយការងារពាក់ព័ន្ធ លើវិស័យថាមពលកកើតឡើងវិញ និង ផ្នែកបច្ចេកវិទ្យាថាមពល ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ដើម្បីសុំមតិណែនាំ និងគោលការណ៍សំរេច ។

www.pheakdeylaw.com

ប្រការ ៤: សមាជិកក្រុមការងារខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន ឬ អនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន ។ ក្នុងករណីសមាជិកណាម្នាក់មិនបានអញ្ជើញចូលរួមប្រជុំ ដោយជាប់រវល់ភារៈកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសំរេចអោយចូលរួមជំនួស ។

ប្រការ ៥: ក្រុមការងារនេះ មានលេខាធិការដ្ឋានមួយប្រចាំនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ព្រមទាំងបណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអោយមានប្រសិទ្ធភាពនូវសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com